ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

# ច្បាប់
# ស្តីពី
# កិច្ចការពារនិង
# លើកកម្ពស់សិទ្ធិជនពិការ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅការពារ និងលើកកម្ពស់សិទ្ធិជនពិការក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២.-**

ច្បាប់នេះ មានគោលបំណង ដូចតទៅ:

-ការពារសិទ្ធិ និងសេរីភាពរបស់ជនពិការ

-ការពារផលប្រយោជន៍ជនពិការ

-ទប់ស្កាត់ កាត់បន្ថយ និងលុបបំបាត់ការរើសអើងជនពិការ

-ស្តារកាយសម្បទា សតិបញ្ញា និងវិជ្ជាជីវៈ ដើម្បីធានាលទ្ធភាពក្នុងការចូលរួមដ៏ពេញលេញ និងដោយស្មើភាពនៃជនពិការក្នុងសកម្មភាពនានារបស់សង្គម។

**មាត្រា ៣.-**

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះជនពិការ និងសកម្មភាពទាំងឡាយណាដែលទាក់ទងនឹងជនពិការនៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៤.-**

វាក្យស័ព្ទសំខាន់ៗ ដែលប្រើនៅក្នុងច្បាប់នេះ មានន័យដូចតទៅ :

- **ជនពិការ** សំដៅដល់ជនទាំងឡាយណាដែលខ្វះខាត បាត់បង់ ខូចខាតសរីរាង្គណាមួយ ឬ សតិបញ្ញា បណ្តាលឱ្យមានការរំខានដល់ជីវភាពរស់នៅ ឬ សកម្មភាពនានាប្រចាំថ្ងៃដូចជាជនពិការរាងកាយ ពិការភ្នែក ពិការក្នុងការស្តាប់ ពិការសតិបញ្ញា មនសិការវិកលនិងប្រភេទពិការផ្សេងៗទៀត ដែលនាំឱ្យមានលក្ខណៈមិនប្រក្រតី។

- **ទីកន្លែងសាធារណៈ** សំដៅដល់បរិវេណ ទីតាំង អគារនិងមធ្យោបាយដឹកជញ្ជូននានា ដែលជាកម្មសិទ្ធិរដ្ឋ សាធារណៈ ឬ ឯកជនដែលបើកទូលាយ និងផ្តល់សេវាដល់សាធារណជនទូទៅ ជាអាទិ៍ៈ ក្រសួង ស្ថាប័ន មន្ទីរ ផ្លូវថ្នល់ កន្លែងលំហែកាយ មជ្ឈមណ្ឌលវប្បធម៌កន្លែងលេងកីឡា កន្លែងកំសាន្ត គ្រឹះស្ថានអប់រំ សណ្ឋាគារ មន្ទីរពេទ្យ មណ្ឌលសុខភាព អាហារដ្ឋាន ប្រព័ន្ធដឹកជញ្ជូន។

- **គ្រឹះស្ថានសិក្សាសាធារណៈ** សំដៅដល់សាលាសាធារណៈ ដែលបានធ្វើការអប់រំបណ្តុះបណ្តាលសិស្សគ្រប់វ័យ។ គ្រឹះស្ថានសិក្សាសាធារណៈ រាប់បញ្ចូលចាប់ពីកម្រិតមត្តេយ្យសិក្សាឡើងទៅ។

- **គ្រឹះស្ថានសិក្សាឯកជន** សំដៅដល់សាលាឯកជន ឬ អង្គការទាំងឡាយណាដែលបានទទួលការអនុញ្ញាតឱ្យ បង្កើត សម្រាប់ធ្វើការអប់រំបណ្តុះបណ្តាលសិស្សគ្រប់វ័យ។

## ជំពូកទី ២
## ក្រុមប្រឹក្សាសកម្មភាពជនពិការនិងរដ្ឋបាលសិទ្ធិជនពិការ

**មាត្រា ៥.-**

ត្រូវបានបង្កើតក្រុមប្រឹក្សាសកម្មភាពជនពិការ មានអក្សរកាត់ថា (ក.ស.ជ) ជាយន្តការសម្របសម្រួលថ្នាក់ជាតិ និងពិគ្រោះយោបល់លើបញ្ហាពិការភាព។

**មាត្រា ៦.-**

ក្រុមប្រឹក្សាសកម្មភាពជនពិការ មានភារកិច្ចដូចខាងក្រោមៈ

-ផ្តល់ការពិគ្រោះយោបល់ជំនាញលើបញ្ហាពិការភាព និងការស្តារលទ្ធភាពពលកម្ម

-ជួយក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធ ក្នុងការរៀបចំគោលនយោបាយផែនការជាតិ និងយុទ្ធសាស្ត្រដែលមានការពាក់ព័ន្ធទៅនឹងពិការភាព និងការស្តារលទ្ធភាពពលកម្ម

-ជម្រុញការអនុវត្តគោលនយោបាយ ច្បាប់ និងបទបញ្ជាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាព និងការស្តារលទ្ធភាពពលកម្ម

-លើកសំណើកែសម្រួល បំពេញបន្ថែម ធ្វើវិសោធនកម្មគោលនយោបាយច្បាប់ និង បទបញ្ជាផ្សេងៗ ពាក់ព័ន្ធនឹងបញ្ហាពិការភាព

-តាមដាន វាយតម្លៃការអនុវត្តគោលនយោបាយ ផែនការជាតិ ច្បាប់ និងបទបញ្ជាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាព

-ទំនាក់ទំនងជាមួយសហគមន៍ជាតិ-អន្តរជាតិ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ កៀរគរប្រភពធនធានទាំងក្នុង និងក្រៅប្រទេស។

**មាត្រា ៧.-**

ក្រុមប្រឹក្សាសកម្មភាពជនពិការរួមមានៈ

-រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច ឬ តំណាង ជាប្រធាន

-តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ

-តំណាងអង្គការជនពិការ

-តំណាងអង្គការនិយោជិក និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើសកម្មភាពជួយដល់ជនពិការ។

ការរៀបចំសមាសភាព និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ៨.-**

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវបង្កើតរដ្ឋបាលសិទ្ធិជនពិការដែលជាអង្គភាពចំណុះនាយកដ្ឋានស្តារលទ្ធភាពពលកម្ម។

**មាត្រា ៩.-**

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដោយសហការជាមួយក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធ មានភារកិច្ចរៀបចំទិវាជនពិការកម្ពុជា និងទិវាកីឡាជនពិការកម្ពុជា ក្នុងគោលបំណងបំផុសការយល់ដឹងជាសាធារណៈអំពីសុខុមាលភាពនៃជនពិការ និងលើកទឹកចិត្តជនពិការ ដើម្បីចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងសកម្មភាពផ្សេងៗទៀត។

ទិវាជនពិការកម្ពុជា និងទិវាកីឡាជនពិការកម្ពុជា ត្រូវប្រារព្ធធ្វើរួមគ្នាជាមួយទិវាជនពិការអន្តរជាតិ ថ្ងៃទី ៣ ខែ ធ្នូ ជារៀងរាល់ឆ្នាំ។

## ជំពូកទី ៣
## ជីវភាពរស់នៅ

**មាត្រា ១០.-**

រដ្ឋត្រូវយកចិត្តទុកដាក់ ជួយលើកតម្កើងជីវភាពរស់នៅរបស់ជនពិការឱ្យ បានសមរម្យស្របតាមស្ថានភាពសេដ្ឋកិច្ចជាតិ។

**មាត្រា ១១.-**

រដ្ឋត្រូវមានវិធានការចាំបាច់នានា ដើម្បីបំផុសលើកទឹកចិត្តពលរដ្ឋ សប្បុរសជនផ្នែកឯកជន និងអង្គការសង្គម ឱ្យ ចូលរួមជួយឧបត្ថម្ភដល់ជនពិការ។

**មាត្រា ១២.-**

រដ្ឋត្រូវរៀបចំគោលនយោបាយផ្គត់ផ្គង់ និងមានថវិកាប្រចាំឆ្នាំ ដើម្បីជួយឧបត្ថម្ភដល់ជនពិការ ដែលៈ

-មានកម្រិតពិការភាពធ្ងន់ធ្ងរ និងក្រីក្របំផុត និងគ្មានទីពឹង ឬ

-ចាស់ជរា និងក្រីក្របំផុត និងគ្មានទីពឹង ឬ

-មានគ្រោះថ្នាក់ធ្ងន់ធ្ងរ និងក្រីក្របំផុត និងគ្មានទីពឹង។

រដ្ឋត្រូវមានថវិកាប្រចាំឆ្នាំ ដើម្បីធ្វើសមាហរណកម្មជនពិការទៅក្នុងសហគមន៍។

**មាត្រា ១៣.-**

មាតា បិតា និងអ្នកអាណាព្យាបាលជនពិការត្រូវ :

-ការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ជនពិការ

-យកចិត្តទុកដាក់បីបាច់ថែរក្សាជនពិការឱ្យ បានល្អ

-លើកទឹកចិត្ត និងជួយជនពិការឱ្យ មានក្តីសង្ឃឹមក្នុងជីវិត។

ការមិនយកចិត្តទុកដាក់ថែទាំ ការកេងប្រវ័ញ្ច និងការបោះបង់ជនពិការ ត្រូវហាមឃាត់។

## ជំពូកទី ៤
## ការស្តារកាយសម្បទា និងសតិបញ្ញា ការថែទាំសុខភាព និងការបង្ការ

**មាត្រា ១៤.-**

រដ្ឋត្រូវរៀបចំកម្មវិធីស្តារកាយសម្បទា និងសតិបញ្ញា សំដៅជួយដល់ជនពិការឱ្យអាចបំពេញមុខងារ និងប្រើប្រាស់សមត្ថភាព ទេពកោសល្យ ក្នុងជីវភាពសង្គម។

**មាត្រា ១៥.-**

រដ្ឋត្រូវបង្កើត និងលើកទឹកចិត្តដល់អង្គការសង្គម និងផ្នែកឯកជនឱ្យ បង្កើតជាអាទិ៍ :

-មជ្ឈមណ្ឌលស្តារកាយសម្បទា និងសតិបញ្ញា

-សាលាសម្រាប់បណ្តុះបណ្តាល អ្នកបច្ចេកទេសផលិត ឧបករណ៍ទ្រទ្រង់រាងកាយ

-មជ្ឈមណ្ឌលផលិតគ្រឿងផ្សំ ឧបករណ៍ទ្រទ្រង់រាងកាយ ដើម្បីធានាសេចក្តីត្រូវការនៃមជ្ឈមណ្ឌលស្តារកាយសម្បទានានា ក្នុងការផ្តល់ឧបករណ៍ទ្រទ្រង់រាងកាយដល់ជនពិការ។

ការបង្កើតមជ្ឈមណ្ឌលស្តារកាយសម្បទា សតិបញ្ញា និងមជ្ឈមណ្ឌលផលិតគ្រឿងផ្សំឧបករណ៍ទ្រទ្រង់រាងកាយ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច។

**មាត្រា ១៦.-**

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច សហការជាមួយក្រសួងទទួលបន្ទុកវិស័យសុខាភិបាល ត្រូវ :

-រៀបចំកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសព្យាបាលដោយចលនា និងព្យាបាលសតិបញ្ញា នៅតាមសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រនានា ហើយបញ្ចូលផ្នែកនេះឱ្យ មានគ្រប់មន្ទីរពេទ្យ ដើម្បីព្យាបាលអ្នកជំងឺកុំឱ្យធ្លាក់ខ្លួនពិការ

-ជួយបណ្តុះបណ្តាលគ្រួសារ ដែលមានសមាជិកពិការ ជនពិការ និងអ្នកស្ម័គ្រចិត្ត អំពីវិធីថែទាំ និងបច្ចេកទេសស្តារលទ្ធភាពពលកម្ម តាមប្រភេទពិការនីមួយៗ ដើម្បីឱ្យគ្រួសារដែលមានសមាជិកពិការ ជនពិការមានលទ្ធភាពស្តារកាយសម្បទា និងសតិបញ្ញាជនពិការ

-ពង្រីកសេវាស្តារលទ្ធភាពពលកម្ម តាមសហគមន៍ សេវាពិគ្រោះយោបល់ព្យាបាលជំងឺផ្លូវចិត្ត និងសតិបញ្ញាខ្សោយ។

**មាត្រា ១៧.-**

រដ្ឋត្រូវបង្កើតកម្មវិធីបង្ការពិការភាព ដល់ពលរដ្ឋគ្រប់រូបតាមរយៈ :

-ការថែទាំសុខភាពក្នុងពេលមានគភ៌

-ការតាមដាន និងការវិនិច្ឆ័យរោគ ដែលនាំឱ្យមានពិការភាព ទាន់ពេលវេលា

-ការផ្តល់ថ្នាំបង្ការជំងឺ ដែលនាំឱ្យមានពិការភាព

-ការផ្តល់អាហារទ្រទ្រង់រាងកាយ

-ការអប់រំអំពីមូលហេតុដែលនាំឱ្យមានពិការភាព

-ការព្យាបាលតាមវិធីវេជ្ជសាស្ត្រ និងការអប់រំកាយសម្បទាឡើងវិញឱ្យទាន់ពេលវេលា។

មាត្រា ១៨.-

ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវបង្កលក្ខណៈឱ្យជនពិការ បានចូលរួមរៀបចំរាល់គម្រោងអភិវឌ្ឍ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលប៉ះពាល់ដល់ផលប្រយោជន៍ជនពិការ។ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវដាក់បញ្ចូលសេចក្តីត្រូវការរបស់ជនពិការទៅក្នុងកម្មវិធី អភិវឌ្ឍននានា។

មាត្រា ១៩.-

គោលនយោបាយជួយឧបត្ថម្ភ សេវាពិនិត្យថែទាំសុខភាព ព្យាបាលនិងស្តារលទ្ធភាពពលកម្មកាយសម្បទាដល់ជនពិការដែលមានពិការភាពធ្ងន់ធ្ងរ ឬ ក្រីក្របំផុតគ្មានទីពឹង ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា ២០.-

លក្ខណវិនិច្ឆ័យប្រភេទ និងកម្រិតនៃពិការភាព ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីបន្ទុកវិស័យសង្គមកិច្ច និងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យសុខាភិបាល។

ការកំណត់លក្ខណវិនិច្ឆ័យ និងកម្រិតនៃពិការភាពរបស់យោធិន ត្រូវមានការចូលរួមពីក្រសួងទទួលបន្ទុកវិស័យការពារជាតិ។

## ជំពូកទី ៥
## ការចេញចូលទីកន្លែងសាធារណៈ

មាត្រា ២១.-

រាល់ទីកន្លែងសាធារណៈ ត្រូវរៀបចំឱ្យមានលក្ខណៈងាយស្រួលចេញចូលសម្រាប់ជនពិការគ្រប់ ប្រភេទ ដូចជាការធ្វើជម្រាល ការបំពាក់ឧបករណ៍ផ្ទាក់ដៃនៅតាមបន្ទប់ទឹក ការដាក់ផ្លាកសញ្ញានានា។

មាត្រា ២២.-

ក្រសួងមានសមត្ថកិច្ចដែលផ្តល់លិខិតអនុញ្ញាតលើគម្រោងសាងសង់ ការសាងសង់និងត្រួតពិនិត្យសំណង់ ទីកន្លែងសាធារណៈ ត្រូវធានាលក្ខណៈងាយស្រួលចេញចូលរបស់ជនពិការ ដូចមានចែងក្នុងមាត្រា ២១ នៃច្បាប់នេះ។

មាត្រា ២៣.-

ការរៀបចំលក្ខណៈងាយស្រួលចេញចូល នៅទីកន្លែងសាធារណៈ ឬ លើមធ្យោបាយដឹកជញ្ជូនផ្សេងៗ សម្រាប់ជនពិការ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យ សង្គមកិច្ច និងក្រសួង ស្ថាប័នពាក់ព័ន្ធ។

មាត្រា ២៤.-

ជនពិការមានសិទ្ធិទទួលប័ណ្ណបើកបរយានយន្ត។ សមត្ថភាពបើកបរយានយន្តនៃជនពិការ ព្រមទាំងប្រភេទយានយន្តសម្រាប់ជនពិការ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសាធារណការ និង

ដឹកជញ្ជូន និងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យសុខាភិបាល។

**មាត្រា ២៥.-**

ក្រសួងទទួលបន្ទុកវិស័យសាធារណការ និងដឹកជញ្ជូន ត្រូវចេញប័ណ្ណសម្គាល់យានយន្ត និងប័ណ្ណបើកបរពិសេសដល់ជនពិការ។ ជនពិការដែលបើកបរយានយន្ត អាចដាក់បង្ហាញប័ណ្ណបើកបរ ឬប័ណ្ណសម្គាល់យានយន្តនៅជាប់នឹងយានយន្តរបស់ខ្លួន ដើម្បីឱ្យអ្នកដទៃមើលឃើញ។

ជនពិការត្រូវដាក់បង្ហាញប័ណ្ណនេះនៅជាប់នឹងយានយន្ត នៅពេលចតលើចំណតសម្រាប់ជនពិការ។

ការក្លែងបន្លំ ឬ ការបំពាន ដើម្បីទទួលបានសិទ្ធិ និងអាទិភាពនេះ ត្រូវហាមឃាត់។

**មាត្រា ២៦.-**

រាល់ទីកន្លែងសាធារណៈ ដែលមានចំណតយានយន្ត ត្រូវរៀបចំឱ្យ មានចំណតយានយន្តពិសេសសម្រាប់ជនពិការ។

រាល់ទីកន្លែងសាធារណៈ ដែលមានបន្ទប់អនាម័យ ត្រូវរៀបចំឱ្យ មានបន្ទប់អនាម័យសម្រាប់ជនពិការ។

ការរៀបចំចំណតយានយន្តសម្រាប់ជនពិការ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសាធារណការ និងដឹកជញ្ជូន។

## ជំពូកទី ៦

## ការអប់រំ

**មាត្រា ២៧.-**

សិស្ស-និស្សិតពិការគ្រប់រូប មានសិទ្ធិចូលសិក្សាក្នុងគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន និងមានសិទ្ធិទទួលអាហារូបករណ៍ដូចសិស្ស-និស្សិតដទៃទៀតដែរ លើកលែងតែមានបញ្ញត្តិផ្ទុយពីនេះ។

**មាត្រា ២៨.-**

រដ្ឋត្រូវបង្កើតគោលនយោបាយ និងយុទ្ធសាស្ត្រជាតិ សម្រាប់អប់រំសិស្ស-និស្សិតពិការដូចជា :

-ការជំរុញធ្វើសមាហរណកម្ម សិស្ស-និស្សិតពិការ ទៅក្នុងថ្នាក់រៀនចម្រុះតាមដែលអាចធ្វើទៅបាន

-ការបង្កើតថ្នាក់រៀនពិសេស សម្រាប់ឆ្លើយតបនឹងសេចក្តីត្រូវការនៃសិស្សនិស្សិតពិការ។

**មាត្រា ២៩.-**

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវរៀបចំកម្មវិធីសម្រាប់គ្រឹះស្ថានសិក្សានានាក្នុងការ សម្របសម្រួលដល់សិស្ស-និស្សិតពិការនូវផ្នែកមួយចំនួន ដូចជា :

-អគារ បន្ទប់ និងកន្លែងសិក្សា

-ភាសាសញ្ញា និងអក្សរស្ទាប

-បច្ចេកទេសអប់រំ និងគរុកោសល្យ ស្របទៅតាមប្រភេទពិការភាព

-សម្ភារៈសិក្សា ឬ ឧបករណ៍ផ្សេងៗ សម្រាប់ជំនួយដល់សិស្ស-និស្សិតពិការ

-សម្ភារៈឧបទេសសម្រាប់គ្រូបង្រៀន ឬ សាស្ត្រាចារ្យ និងផ្នែកផ្សេងៗទៀតតាមការជាក់ស្តែងរបស់សិស្ស-និស្សិតពិការម្នាក់ៗ។

**មាត្រា ៣០.-**

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវយកចិត្តទុកដាក់ជាពិសេសដល់សេចក្តីត្រូវការផ្នែកអប់រំរបស់សិស្ស-និស្សិតពិការ។

សិស្ស-និស្សិតពិការក្នុងគ្រួសារក្រីក្រ ឬ ជាយោធិនពិការ ត្រូវបានទទួលដោយឥតគិតថ្លៃនូវការចូលសិក្សានៅតាមគ្រឹះស្ថាន សិក្សាសាធារណៈគ្រប់កម្រិតសិក្សា និងសៀវភៅសិក្សាព្រមទាំងសម្ភារៈសិក្សា។

គ្រឹះស្ថានសិក្សាឯកជន ត្រូវមានគោលការណ៍ពិសេសចុះថ្លៃការសិក្សា សៀវភៅសិក្សានិងសម្ភារៈសិក្សាសម្រាប់សិស្ស-និស្សិតពិការ ឬ ជាយោធិនពិការ។

ការកំណត់ការចុះថ្លៃការសិក្សា និងសម្ភារៈសិក្សា ត្រូវចែងដោយប្រកាសរួមរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច និងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យអប់រំ។

**មាត្រា ៣១.-**

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវដាក់បញ្ចូលក្នុងកម្មវិធីបញ្ជ្រាបការសិក្សា ជាអាទិ៍ : អំពីមូលហេតុនៃពិការភាព វិធីបង្ការ និងតម្លៃរបស់ជនពិការ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវមានកម្មវិធីគរុកោសល្យអំពីពិការភាពសម្រាប់បំពាក់បំប៉នគ្រូ និងសាស្ត្រាចារ្យគ្រប់រូបឱ្យ យល់ដឹងពីពិការភាព និងវិធីសាស្ត្របង្រៀនសិស្ស-និស្សិតពិការ។

**មាត្រា ៣២.-**

ក្រសួងទទួលបន្ទុកវិស័យព័ត៌មាន ត្រូវផ្សព្វផ្សាយឱ្យ បានទូលំទូលាយនូវការយល់ដឹងជាសាធារណៈអំពីពិការភាពនិងសិទ្ធិជន ពិការ ដើម្បីពង្រឹងសាមគ្គីភាព ការយោគយល់ និងការគោរពសិទ្ធិជនពិការ តាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ដោយឥតបង់ថ្លៃ។

ចំពោះប្រព័ន្ធផ្សព្វផ្សាយឯកជន ត្រូវមានកម្មវិធីផ្សព្វផ្សាយពិសេសចូលរួមយ៉ាងសកម្មក្នុងសកម្មភាពខាងលើ។

## ជំពូកទី ៧
## ការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ

**មាត្រា ៣៣.-**

ជនពិការដែលមានលក្ខណសម្បត្តិ និងសមត្ថភាពបំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែង មានសិទ្ធិចូលបម្រើការងារ ដោយគ្មានការរើសអើងរាប់ទាំងការបម្រើការងារជាមន្ត្រីរាជការ កម្មករ និយោជិត កូនជាង ឬ កម្មសិក្សាការី។

**មាត្រា ៣៤.-**

នីតិបុគ្គលដែលជ្រើសរើសកម្មករ និយោជិតធ្វើការ ត្រូវទទួលយកជនពិការដូចមានចែងក្នុងមាត្រា ៣៣ នៃ

ច្បាប់នេះ ឱ្យចូលធ្វើការតាមអត្រាកំណត់សមស្រប។

អត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីទទួលបន្ទុកវិស័យការងារ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

**មាត្រា ៣៥.-**

ក្រសួង ស្ថាប័នរដ្ឋ ដែលជ្រើសរើសមន្ត្រីរាជការឱ្យ ចូលធ្វើការងារ ត្រូវជ្រើសរើសជនពិការ ដូចមានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះ ក្នុងអត្រាកំណត់សមស្រប។

អត្រា និងបែបបទជ្រើសរើស ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ៣៦.-**

នីតិបុគ្គលដែលទទួលជនពិការ ឱ្យចូលធ្វើការតាមអត្រាកំណត់សមស្រប ត្រូវធ្វើសេចក្តីជូនដំណឹងជាទៀងទាត់អំពីចំនួនកម្មករនិយោជិត ធ្វើការទាំងអស់ និងកម្មករ និយោជិតជាជនពិការទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច និងក្រសួងទទួលបន្ទុកវិស័យការងារ។

**មាត្រា ៣៧.-**

នីតិបុគ្គលដែលមិនអាចបំពេញតាមកាតព្វកិច្ច ដូចមានចែងក្នុងមាត្រា ៣៤ និងមាត្រា ៣៥ នៃច្បាប់នេះ ត្រូវបង់ភាគទានចូលហិបមូលនិធិនៃជនពិការ។

អត្រានៃការបង់ភាគទាន ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

**មាត្រា ៣៨.-**

នីតិបុគ្គលត្រូវរៀបចំឱ្យមានការសម្របសម្រួលសមស្រប សម្រាប់ជនពិការ ដែលជាបេក្ខជនដាក់ពាក្យសុំបម្រើការងារ ជាកម្មករ និយោជិត ឬ កូនជាង ឬ កម្មសិក្សាការី លើកលែងតែក្នុងករណីការសម្របសម្រួលនោះមានបន្ទុកធ្ងន់ធ្ងរហួសហេតុ។

**មាត្រា ៣៩.-**

រដ្ឋត្រូវយកចិត្តទុកដាក់បង្កើតស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ជនពិការ។

គ្រឹះស្ថានអប់រំ បណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈរបស់រដ្ឋ ឯកជន ឬ អង្គការនានា ត្រូវទទួលបណ្តុះបណ្តាលជនពិការឱ្យចូលសិក្សាដោយបង់ថ្លៃ តាមអត្រាកំណត់សមស្របឬ ដោយឥតបង់ថ្លៃ សម្រាប់ជនពិការក្រីក្រ ឬ ជាយោធិនពិការ។

អត្រានេះ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គម កិច្ច និងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា ៤០.-**

គ្រឹះស្ថានអប់រំ បណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈរបស់រដ្ឋ ឯកជន ឬ អង្គការនានា ត្រូវរៀបចំការសម្របសម្រួលសមស្របដល់ជនពិការ ដែលជាបេក្ខជនដាក់ពាក្យសុំចូលសិក្សា ឬ ជាសិក្ខាកាម ឬ ជាកម្មសិក្សាការី លើកលែងតែក្នុងករណីការសម្របសម្រួលនោះ មានបន្ទុកធ្ងន់ធ្ងរហួសហេតុ។

មាត្រា ៤១.-

គ្រឹះស្ថានអប់រំ បណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈរបស់រដ្ឋ ឯកជន ឬ អង្គការនានា ត្រូវរៀបចំកម្មវិធីបណ្តុះបណ្តាលលំអិតជាលាយលក្ខណ៍អក្សរ រួចប្រកាសផ្សាយឱ្យជនពិការដឹងជាមុន។ កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនេះ ត្រូវផ្ញើជូនស្ថាប័នមានសមត្ថកិច្ចដើម្បីធានាការអនុវត្តឱ្យ បានត្រឹមត្រូវ។

## ជំពូកទី ៨
## ការលើកទឹកចិត្ត

មាត្រា ៤២.-

រដ្ឋត្រូវលើកទឹកចិត្តដល់ជនពិការ ដែលប្រកបមុខរបរ អាជីវកម្ម សិប្បកម្មជាលក្ខណៈឯកត្តជន ឬ គ្រួសារ ឬ សមូហភាពរបស់ជនពិការ តាមរយៈការកាត់បន្ថយពន្ធដារ និងការផ្តល់អាទិភាពផ្សេងៗទៀត ស្របតាមច្បាប់ជាធរមាន។

មាត្រា ៤៣.-

រដ្ឋត្រូវលើកទឹកចិត្តផ្នែកពន្ធដារ និងលើកទឹកចិត្តផ្សេងៗទៀត ស្របតាមច្បាប់ជាធរមានដល់និយោជក គ្រឹះស្ថានសិក្សា គ្រឹះស្ថានអប់រំ បណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈដែលបានទទួលជនពិការឱ្យចូលធ្វើការ អប់រំ បណ្តុះបណ្តាល ទៅតាមអត្រាកំណត់សមស្រប ឬលើសអត្រាកំណត់សមស្រប ដែលមានចែងក្នុងជំពូកទី ៧ នៃច្បាប់នេះ។

## ជំពូកទី ៩
## ការបោះឆ្នោត

មាត្រា ៤៤.-

ជនពិការគ្រប់រូប មានសិទ្ធិចូលរួមក្នុងការបោះឆ្នោត ឬ ឈរឈ្មោះជាបេក្ខជនឱ្យ គេបោះឆ្នោត ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការបោះឆ្នោតជាធរមាន។

មាត្រា ៤៥.-

ការប្រមាថ ការរើសអើង ចំពោះពិការភាពរបស់បេក្ខជន ត្រូវហាមឃាត់។

## ជំពូកទី ១០
## មូលនិធិជនពិការ

មាត្រា ៤៦.-

ត្រូវបង្កើតមូលនិធិជនពិការ ជាគ្រឹះស្ថានរដ្ឋបាលសាធារណៈ ក្នុងគោលបំណងដូចតទៅ:

១- ផ្តល់មូលនិធិសម្រាប់ការអនុវត្តគម្រោងកម្មវិធីផ្សេងៗ ដែលជួយដល់ជនពិការ និងគាំទ្រដល់ស្ថាប័ន គ្រឹះស្ថាននានា ដែលផ្តល់សេវាកម្មដល់ជនពិការ ដូចជាផ្នែកសុខាភិបាល ស្តារលទ្ធភាពពលកម្ម អប់រំ បណ្តុះបណ្តាលបច្ចេកទេស វិជ្ជាជីវៈ និងការរកការងារឱ្យធ្វើ។

២- លើកកម្ពស់ និងបង្កើនសុខុមាលភាពរបស់ជនពិការ ជាពិសេស:

-ជនពិការក្រីក្រ និងយោធិនពិការ ដែលមិនបានទទួលសេវាស្តារលទ្ធភាពពលកម្ម

-គ្រួសារជនពិការក្រីក្រ និងយោធិនពិការ ដែលពឹងផ្អែកលើជនពិការក្នុងជីវភាពរស់នៅ

-ជនពិការក្រីក្រ និងយោធិនពិការ ដែលបានទទួលសេវាស្តារលទ្ធភាពពលកម្ម ឬ ជនពិការ ដែលមានជំនាញតែពុំទាន់ទទួលបានការងារធ្វើ។

៣- ផ្តល់ប្រាក់កម្ចីសម្រាប់ការសម្របសម្រួលសមស្រប។

**មាត្រា ៤៧.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជនពិការ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ៤៨.-**

មូលនិធិជនពិការ មានប្រភពចំណូលមកពីការឧបត្ថម្ភ និងអំណោយរបស់រាជរដ្ឋាភិបាល ស្ថាប័ន គ្រឹះស្ថាន អង្គការជាតិ អង្គការអន្តរជាតិ សប្បុរសជននានា គ្រប់មជ្ឈដ្ឋាន និងភាគទាន ដែលមានចែងក្នុងមាត្រា ៣៧ នៃច្បាប់នេះ។

## ជំពូកទី ១១
## ការអនុវត្តសន្ធិសញ្ញាអន្តរជាតិ

**មាត្រា ៤៩.-**

បទប្បញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញាអន្តរជាតិទាក់ទងនឹងច្បាប់ស្តីពី កិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ដែលព្រះរាជាណាចក្រកម្ពុជាជាភាគី ត្រូវយកមកអនុវត្តជាមួយច្បាប់នេះ។

ក្នុងករណីមានទំនាស់ជាមួយនឹងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ បទប្បញ្ញត្តិនៃសន្ធិសញ្ញាអន្តរជាតិទាំងនោះ ត្រូវចាត់ទុកជាបទប្បញ្ញត្តិគោល។

## ជំពូកទី ១២
## ទោសប្បញ្ញត្តិ

**មាត្រា ៥០.-**

អំពើប៉ះពាល់ដល់ការប្រើប្រាស់ដោយសេរីនូវសិទ្ធិបោះឆ្នោត ឬ ដល់និយ័តភាពនៃការបោះឆ្នោតរបស់ជនពិការ ដោយប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬ ឧបាយកលទុច្ចរិត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។

បទល្មើសនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និង ពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ប្រសិនបើបទល្មើសនេះបានប្រព្រឹត្តដោយមានការប្រើអាវុធ។

**មាត្រា ៥១.-**

អំពើរបស់បុគ្គល ដែលមានកាតព្វកិច្ចថែរក្សា ដែលបោះបង់ជនពិការដោយចេតនាអមនុស្សធម៌ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ប្រសិនបើអំពើបោះបង់បណ្តាលឱ្យអន្តរាយដល់សុខភាព ឬ សន្តិសុខរបស់

ជនពិការ។

មាត្រា ៥២.-

អំពើរបស់ជនគ្រប់រូប ដែលមានអំណាចទៅលើជនពិការ ដែលបង្អត់អាហារ ឬ គ្មានការថែទាំរហូតដល់ខូចសុខភាពជនពិការនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល។

មាត្រា ៥៣.-

អំពើទាញយកប្រយោជន៍ដោយចេតនា ដោយរំលោភលើភាពល្ងង់ខ្លៅ ឬ ភាពទន់ខ្សោយនៃបុគ្គលនេះ បណ្តាលមកពីស្ថានភាពពិការភាព ដោយបង្ខំបុគ្គលនេះឱ្យប្រព្រឹត្តអំពើឬ មិនប្រព្រឹត្តអំពើ ដែលធ្វើឱ្យខូចប្រយោជន៍យ៉ាងធ្ងន់ធ្ងររបស់បុគ្គលនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀលទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។

មាត្រា ៥៤.-

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ចំពោះនីតិបុគ្គលដែលមិនព្រមបង់ចូលហិបមូលនិធិជនពិការ ដូចមានកំណត់នៅក្នុងមាត្រា ៣៧ នៃច្បាប់នេះ ដោយគ្មានមូលហេតុសមស្រប។

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ចំពោះប្រធានស្ថាប័នរដ្ឋដែលមិនព្រមអនុវត្តមាត្រា ៣៥ នៃច្បាប់នេះដោយគ្មានមូលហេតុសមស្រប។

ការពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។

មាត្រា ៥៥.-

ការក្លែងបន្លំប័ណ្ណសម្គាល់យានយន្ត ឬ ប័ណ្ណបើកបរពិសេសសម្រាប់ជនពិការ ឬ អំពើប្រព្រឹត្តដោយទុច្ចរិត ដើម្បីទទួលបានសិទ្ធិ និងអាទិភាពដូចមានចែងក្នុងមាត្រា ២៥ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និង ពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល។

មាត្រា ៥៦.-

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល អំពើជ្រៀតជ្រែកដោយខុសច្បាប់ ទៅក្នុងការអនុវត្តមុខងារសាធារណៈណាមួយ ដោយបំពេញកិច្ចណាមួយក្នុងចំណោមកិច្ចទាំងឡាយ ដែលសម្រាប់តែអ្នកមានសិទ្ធិក្នុងមុខងារនេះ។

## ជំពូកទី ១៣
## អន្តរប្បញ្ញត្តិ

មាត្រា ៥៧.-

ទីកន្លែងសាធារណៈទាំងឡាយណា ដែលបានសាងសង់ មុនច្បាប់នេះចូលជាធរមានហើយដែលមានលទ្ធភាព ត្រូវរៀបចំកែសម្រួលទីកន្លែងសាធារណៈនោះ យ៉ាងយូររយៈពេល៥ (ប្រាំ) ឆ្នាំ ដើម្បីឱ្យជនពិការមាន

លក្ខណៈងាយស្រួលចេញ-ចូលបាន។

ក្នុងករណីមិនគោរពតាមវាក្យខ័ណ្ឌខាងលើ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល។

**មាត្រា ៥៨.-**

ទីកន្លែងសាធារណៈទាំងឡាយណា ដែលបានសាងសង់មុនច្បាប់នេះចូលជាធរមានហើយមិនទាន់បានរៀបចំ ដូចមានចែងក្នុងមាត្រា ២៦ នៃច្បាប់នេះ ហើយដែលមានលទ្ធភាពត្រូវរៀបចំកែសម្រួលទីកន្លែងសាធារណៈនោះ យ៉ាងយូររយៈពេល ៥ (ប្រាំ) ឆ្នាំ។

ក្នុងករណីមិនគោរពតាមវាក្យខ័ណ្ឌខាងលើ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល។

**មាត្រា ៥៩.-**

ក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ដែលជ្រើសរើសបុគ្គលិកចូលបម្រើការងារ ដូចមានចែងក្នុងមាត្រា ៣៤ និងមាត្រា ៣៥ នៃច្បាប់នេះ ត្រូវចាប់អនុវត្តក្នុងរយៈពេល១ (មួយ) ឆ្នាំក្រោយច្បាប់នេះចូលជាធរមាន។

## ជំពូកទី ១៤
## អវសានប្បញ្ញត្តិ

**មាត្រា ៦០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលចែងក្នុងផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

ច្បាប់នេះ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ៤ ។

ភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៩

**ប្រធានរដ្ឋសភា**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:....០៧....[illegible].៩២៥

## សេចក្តីថ្លែងហេតុ
## នៃសេចក្តីព្រាងច្បាប់ ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ

ប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាម និងរបបប្រល័យពូជសាសន៍ ហើយបានបន្សល់ទុកផលវិបាកជាច្រើន ក្នុងនោះមានអត្រាជនពិការខ្ពស់។ គ្រោះថ្នាក់ដោយសារគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ គ្រោះថ្នាក់ចរាចរ គ្រោះថ្នាក់ការងារកង្វះអាហារូបត្ថម្ភ និងជំងឺតម្កាត់ ក៏ជាហេតុនាំឱ្យមានជនពិការច្រើនដែរ។ យោងតាមស្ថិតិក្រៅផ្លូវការ ប្រទេសយើងមានជនពិការប្រមាណ ២% នៃចំនួនប្រជាជនសរុប ហើយជនពិការទាំងនោះ ជាជនក្រីក្របំផុត ក្នុងចំណោមជនក្រីក្រដែលងាយទទួលរងគ្រោះជាងគេ នៅក្នុងសង្គម។

កន្លងមក រាជរដ្ឋាភិបាលបានខិតខំធ្វើការងារជាច្រើន ដើម្បីជួយដោះស្រាយសេចក្តីត្រូវការរបស់ជនពិការ ដោយបានដាក់ឱ្យ អនុវត្តនូវគោលនយោបាយ និងលិខិតបទដ្ឋានជាច្រើនជាបន្តបន្ទាប់។ ទន្ទឹមនេះដែរ អតីតយុទ្ធជនពិការដោយសារសង្គ្រាម បានទទួលរបបឧបត្ថម្ភពីរដ្ឋ ជនពិការគ្រប់ប្រភេទ បានទទួលសេវាស្តារលទ្ធភាពពលកម្មកាយសម្បទា ដោយឥតគិតថ្លៃពីសំណាក់រាជរដ្ឋាភិបាលដែលបានសហការជាមួយអង្គការ ដៃគូ បង្កើតមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម និងបណ្តុះបណ្តាលវិជ្ជាជីវៈជាច្រើន សម្រាប់ជួយដល់ជនពិការដូចជា បង្កើតសេវាអក្សរស្ទាប ភាសាសញ្ញាដើម្បីឆ្លើយតបតម្រូវការនៃប្រភេទពិការភាព។ ទិវាពិការ ០៣ធ្នូ ត្រូវបានប្រារព្ធជាផ្លូវការរៀងរាល់ឆ្នាំ ហើយចលនាកីឡាជនពិការក៏បានទទួលលទ្ធផលល្អជាច្រើន។ ជនពិការមានសកម្មភាពជួយខ្លួនឯង ដូចជា ការបង្កើតសមាគមអតីតយុទ្ធជន អង្គការជនពិការ និងសេវាសហគមន៍ បានបង្កើនការអនុវត្តសិទ្ធិចូលរួមរបស់ជនពិការ កាត់បន្ថយការរើសអើង ចំពោះជនពិការ ដោយផ្តល់ឱកាស និងសិទ្ធិស្មើភាព ដល់ជនពិការក្នុងការចូលរួមចំណែកកសាង និងអភិវឌ្ឍន៍ប្រទេសជាតិរបស់ខ្លួន។

សេចក្តីព្រាងច្បាប់ ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ បានតាក់តែងឡើង ដោយអនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៧៤ ដែលចែងថា "រដ្ឋជួយឧបត្ថម្ភជនពិការ និងដល់គ្រួសារយុទ្ធជនដែលបានបូជាជីវិត ដើម្បីប្រទេសជាតិ"។

កម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៣ នៃរដ្ឋសភា បានកំណត់គោលការណ៍ វិធានការ ដើម្បីការពារ និងលើកកម្ពស់សិទ្ធិជនពិការ ដោយបានសម្រេចដាក់បញ្ចូលសកម្មភាពកំចាត់មីននិងការជួយជនពិការដោយ សារមីន និងគ្រាប់មិនទាន់ផ្ទុះ ជាគោលដៅមួយក្នុងចំណោមគោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជា ហើយនិងបានបញ្ជាក់ក្នុងសារលិខិតជូនជនពិការ និងជនរួមជាតិ ក្នុងទិវាជនពិការអន្តរជាតិថ្ងៃទី០៣ ខែធ្នូ ជារៀងរាល់ឆ្នាំ ថា រាជរដ្ឋាភិបាលកម្ពុជានឹងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការដើម្បីលើកស្ទួយសិទ្ធិជនពិការ និងជីវភាពរស់នៅរបស់បងប្អូនពិការឱ្យបាន

ប្រសើរឡើង។

សេចក្តីព្រាង ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ អាចជួយឱ្យគ្រប់ផ្នែក និងវិស័យទាំងអស់ស្រូបទាញយកសក្តានុពលភាពរបស់ជនពិការ ហើយជួយដល់ជនពិការ និងសាធារណៈជន ឱ្យមានការយល់ដឹង មានទំនុកចិត្ត និងមានសេចក្តីសង្ឃឹម ហើយអាចផ្លាស់ប្តូរផ្នត់គំនិត ឬទស្សនៈ ដែលយល់ថា ជនពិការជាជនត្រូវស្ថិតទាំងស្រុងក្នុងការទទួលខុសត្រូវ និងបន្ទុកគ្រួសារ និងសង្គម។

សេចក្តីព្រាងច្បាប់នេះ មាន ១៤ ជំពូក ៦០មាត្រា ដែលមានខ្លឹមសារសង្ខេប ដូចតទៅ:

ជំពូកទី ១ : ស្តីពីបទប្បញ្ញត្តិទូទៅ មាន ៤ មាត្រា។ នៅក្នុងជំពូកនេះ ចែងអំពីគោលដៅ គោលបំណង វិសាលភាព និងការកំណត់និយមន័យ នៃវាក្យស័ព្ទសំខាន់ៗ ដែលប្រើនៅក្នុងច្បាប់នេះ។

ជំពូកទី ២ : ស្តីពីក្រុមប្រឹក្សាសកម្មភាពជនពិការ និងរដ្ឋបាលសិទ្ធិជនពិការ មាន ៥មាត្រា។ នៅក្នុង ជំពូកនេះ ចែងអំពីតួនាទី ភារកិច្ច និងសមាសភាពរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការដែលជាយន្តការ សម្របសម្រួលថ្នាក់ជាតិ និងពិគ្រោះយោបល់លើបញ្ហាពិការភាព កំណត់ស្ថាប័នមានសមត្ថកិច្ចក្នុងការបង្កើតរដ្ឋបាលសិទ្ធិជនពិការ និងការរៀបចំទិវាជនពិការកម្ពុជា និងទិវាកីឡាជនពិការកម្ពុជា។

ជំពូកទី ៣ : ស្តីពីជីវភាពរស់នៅ មាន ៤ មាត្រា។ នៅក្នុងជំពូកនេះ ចែងអំពីការយកចិត្តទុកដាក់របស់ រដ្ឋក្នុងការជួយលើកតម្កើងជីវភាពរស់នៅរបស់ជនពិការឱ្យបាន សមរម្យ ស្របតាមស្ថានភាពសេដ្ឋកិច្ចជាតិ និងចែងអំពីកាតព្វកិច្ចរបស់មាតាបិតា ឬអាណាព្យាបាលជនពិការពាក់ព័ន្ធនឹងការងារ មួយចំនួនដូចជា : ការការពារសិទ្ធិ និងអត្ថប្រយោជន៍ស្របច្បាប់របស់ជនពិការ ការបីបាច់ថែរក្សា ការលើកទឹកចិត្ត ឱ្យជនពិការមានសង្ឃឹមក្នុងជីវិត និងតម្រូវឱ្យស្ថាប័នមានសមត្ថកិច្ចចាត់វិធានការក្នុងហាមឃាត់ ចំពោះការមិនយកចិត្តទុកដាក់ ការកេងប្រវ័ញ្ច ការមិនអើពើ និងការបោះបង់ជនពិការចោល។ ការចាត់វិធានការ ឱ្យមានការចូលរួមពីប្រជាពលរដ្ឋ សហគមន៍ សប្បុរសជន អង្គការសង្គម ដើម្បីជួយឧបត្ថម្ភដល់ជនពិការ និងរៀបចំឱ្យមានគោលនយោបាយផ្គត់ផ្គង់ សម្រាប់ជួយដល់ជនពិការដែលក្រីក្រគ្មានទីពឹង និងការជំរុញដល់ការងារសមាហរណកម្មជនពិការទៅក្នុងសហគមន៍។

ជំពូកទី ៤ : ស្តីពីការស្តារកាយសម្បទា និងសតិបញ្ញា ការថែទាំសុខភាព និងការបង្ការ មាន ៧ មាត្រា។ ក្នុងជំពូកនេះចែងអំពីកាតព្វកិច្ចរបស់ស្ថាប័នរដ្ឋ ក្នុងការរៀបចំកម្មវិធីស្តារកាយសម្បទា និងសតិបញ្ញា ការបង្ការ និងការថែទាំសុខភាព ផ្តល់ជូនជនពិការ និងការកំណត់ស្ថាប័នមានសមត្ថកិច្ច ក្នុងការចេញប្រកាសកំណត់លក្ខណៈវិនិច្ឆ័យប្រភេទ និងកម្រិតនៃពិការភាព។ ចំពោះជនពិការ ដែលក្រីក្រគ្មានទីពឹង ឬមានពិការភាពធ្ងន់ធ្ងរ ត្រូវបានទទួលសេវាពិនិត្យថែទាំសុខភាព និងព្យាបាលស្របតាមការរីកចម្រើនសេដ្ឋកិច្ចពីសំណាក់ស្ថាប័នមាន សមត្ថកិច្ច។

ជំពូកទី ៥ : ស្តីពីការចេញចូលទីកន្លែងសាធារណៈ មាន ៦ មាត្រា។ ក្នុងជំពូកនេះ ចែងអំពីការចាត់ វិធានការ ដោយរាប់បញ្ចូលការសាងសង់អាគារ ទីកន្លែងសាធារណៈ មធ្យោបាយធ្វើដំណើរ អាកាសយានដ្ឋាន កំពង់ផែ ចំណតយានយន្ត ដែលត្រូវកំណត់ ដោយស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធ និងការសម្របសម្រួលសមស្រប ដើម្បីឱ្យជនពិការមានលទ្ធភាពចេញចូល ឬធ្វើដំណើរ បើកបរ និងចតយានយន្ត តាមទីកន្លែងសាធារណៈនានា ប្រកបដោយភាពងាយស្រួល និងមានសុវត្ថិភាពបំផុត។

ជំពូកទី ៦ : ស្តីពីការអប់រំ មាន ៦ មាត្រា។ ក្នុងជំពូកនេះ ចែងអំពីការចាត់វិធានការ ដើម្បីឱ្យសិស្ស-និស្សិតពិការគ្រប់រូបមានសិទ្ធិចូលសិក្សាបាន។ ចំពោះសិស្ស-និស្សិតពិការដែលក្រីក្រត្រូវទទួលបានដោយឥតគិតថ្លៃ

នូវការចូលសិក្សានៅតាមគ្រឹះស្ថានសិក្សាសាធារណៈគ្រប់កម្រិតសិក្សា និងសៀវភៅសិក្សា ព្រមទាំងសម្ភារៈសិក្សា។ ជំពូកនេះ ក៏មានចែងអំពី ការបង្កើតយុទ្ធសាស្ត្រ និងគោលនយោបាយជាតិ ដើម្បីជំរុញឱ្យមានការធ្វើសមាហរណកម្មសិស្ស-និស្សិតពិការ ទៅក្នុងថ្នាក់រៀនចម្រុះ ឬការបង្កើតថ្នាក់រៀនពិសេសដើម្បីឆ្លើយតបតម្រូវការរបស់ពិការ និងស្ថាប័នមានសមត្ថកិច្ចត្រូវរៀបចំកម្មវិធីសម្រាប់គ្រឹះស្ថាន សិក្សានានាក្នុងការសម្របសម្រួលដល់សិស្ស-និស្សិតពិការ ការដាក់បញ្ចូលក្នុងកម្មវិធីបញ្ញាបការសិក្សាអំពីមូលហេតុនៃពិការភាព វិធីបង្ការ និងតម្លៃរបស់ជនពិការ ព្រមទាំងរៀបចំឱ្យមានកម្មវិធីគរុកោសល្យអំពីពិការភាពសម្រាប់បំពាក់បំប៉នគ្រូ និងសាស្ត្រាចារ្យឱ្យយល់ដឹងពីពិការភាព និងវិធីសាស្ត្របង្រៀនសិស្ស-និស្សិតពិការ។

ជំពូកទី ៧ : ស្តីពីការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ មាន ៩ មាត្រា។ ក្នុងជំពូកនេះ ចែងអំពី កាតព្វកិច្ចរបស់និយោជក (ស្ថាប័នរដ្ឋ និងឯកជន) ក្នុងការទទួលយកជនពិការឱ្យចូលធ្វើការ តាមអត្រាកំណត់សមស្រប និងដោយគ្មានការរើសអើង និងតម្រូវឱ្យមានគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរបស់រដ្ឋ ឯកជន ឬអង្គការត្រូវទទួលបណ្តុះបណ្តាលជនពិការដោយបង់ថ្លៃតាមអត្រាកំណត់ សមស្រប។

ជំពូកទី ៨ : ស្តីពីការលើកទឹកចិត្ត មាន ២ មាត្រា។ ក្នុងជំពូកនេះ បានតម្រូវឱ្យបង្កើតកម្មវិធីលើក ទឹកចិត្ត ចំពោះជនពិការក្នុងការប្រកបមុខរបរអាជីវកម្ម សិប្បកម្ម ទោះក្នុងលក្ខណៈផ្ទាល់ខ្លួន ជាគ្រួសារ ឬជាសមូហភាពក្តី។ ការលើកទឹកចិត្តនេះ ក៏ត្រូវធ្វើចំពោះនិយោជក ឬម្ចាស់សហគ្រាសណា ដែលបានទទួលយកជនពិការឱ្យចូលធ្វើការ តាមអត្រាកំណត់ ឬលើសអត្រាកំណត់ ផងដែរ។

ជំពូកទី ៩ : ស្តីពីការបោះឆ្នោត មាន ២ មាត្រា។ ក្នុងជំពូកនេះ ចែងអំពីសិទ្ធិស្របច្បាប់របស់ជនពិការ ក្នុងការបោះឆ្នោតនិងឈរឈ្មោះឱ្យគេបោះឆ្នោត ស្របតាមច្បាប់ស្តីពីការបោះឆ្នោត ជាធរមាន និងបានហាមឃាត់ទង្វើដែលជាការប្រមាថ ការរើសអើង ចំពោះពិការភាពរបស់បេក្ខជនឈរឈ្មោះ ឱ្យគេបោះឆ្នោត។

ជំពូកទី ១០ : ស្តីពីមូលនិធិជនពិការ មាន ៣ មាត្រា។ ក្នុងជំពូកនេះ ចែងអំពីការបង្កើតមូលនិធិ ជនពិការ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលត្រូវបង្កើតដោយអនុក្រឹត្យ និងមានតួនាទីប្រមែប្រមូលថវិកា និងផ្តល់មូលនិធិសម្រាប់គម្រោងកម្មវិធីនានា ដែលពាក់ព័ន្ធដល់ការការពារសិទ្ធិ និងអត្ថប្រយោជន៍របស់ជនពិការ។

ជំពូកទី១១ : ស្តីពីការអនុវត្តសន្ធិសញ្ញាអន្តរជាតិ មាន ១ មាត្រា។ ក្នុងជំពូកនេះ ចែងអំពីការអនុវត្ត បទប្បញ្ញត្តិនៃសន្ធិសញ្ញាអន្តរជាតិ ទាក់ទងនឹងច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ និងការចាត់ទុកបទប្បញ្ញត្តិនៃសន្ធិសញ្ញាអន្តរជាតិ ជាបទប្បញ្ញត្តិគោល ក្នុងករណីមានទំនាស់។

ជំពូកទី១២ : ស្តីពីទោសប្បញ្ញត្តិ មាន ៧ មាត្រា។ ក្នុងជំពូកនេះ ចែងអំពីការផ្តន្ទាទោស ចំពោះអ្នក ប្រព្រឹត្តល្មើសនឹងបញ្ញត្តិទាំងឡាយ ដែលមានចែងក្នុងច្បាប់នេះ ដូចជា អំពើទាញយកផលប្រយោជន៍ពីជនពិការ ការបោះបង់ជនពិការ ការក្លែងបន្លំ ឬការបំពាន ដើម្បីទទួលបានសិទ្ធិ និងអាទិភាពរបស់ជនពិការ ក្នុងការបើកបរយានយន្ត ការមិនបានបំពេញកាតព្វកិច្ចរបស់នីតិបុគ្គលក្នុងការទទួលយក ជនពិការចូលបម្រើការងារតាមក្រុមហ៊ុន រោងចក្រ សហគ្រាស ពិសេសអំពើប៉ះពាល់ដល់ការប្រើប្រាស់ដោយសេរីនូវសិទ្ធិបោះឆ្នោត ឬនិយ័តភាពនៃការបោះឆ្នោតរបស់ជនពិការ ដោយប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬឧបាយកលទុច្ចរិត។ ការផ្តន្ទាទោសលើអំពើទាំងនេះ រួមមាន ការផ្តន្ទាទោសដាក់ពន្ធនាគារ ក្នុងកម្រិតអប្បបរិមា ១ (មួយ) ឆ្នាំ និងអតិបមា ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ ក្នុងកម្រិតអប្បបរិមា ១០០.០០០

(មួយសែន) រៀល និងអតិបរមា ១០.០០០.០០០ (ដប់លាន) រៀល។

ជំពូកទី១៣: ស្តីពីអន្តរប្បញ្ញតិមាន ៣ មាត្រា។ ក្នុងជំពូកនេះ តម្រូវឱ្យរាល់ទីកន្លែងសាធារណៈ ដែល បានសាងសង់មុនច្បាប់នេះចូលជាធរមាន ត្រូវរៀបចំកែសម្រួលលក្ខណៈងាយស្រួលចេញចូល និងចំណតយានយន្តសម្រាប់ជនពិការ ក្នុងរយៈពេល ៥ ឆ្នាំ។ ក្នុងករណីមិនគោរពតាមបញ្ញត្តិនេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល។

ជំពូកទី១៤ : ស្តីពីអវសានប្បញ្ញត្តិ មាន ១ មាត្រា។ ក្នុងជំពូកនេះ ចែងអំពីការនិរាករណ៍ទោសប្បញ្ញត្តិ ដែលមានចែងនៅក្នុងជំពូកទី ១២ នៃច្បាប់នេះ នៅពេលដែលក្រមព្រហ្មទណ្ឌចូលជាធរមាន។

សរុបសេចក្តីមក ការបង្កើតច្បាប់ ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ នៅព្រះរាជាណាចក្រកម្ពុជា គឺជាតម្រូវការចាំបាច់សម្រាប់ការលើកកម្ពស់គុណភាពវិស័យ សង្គមកិច្ចជាតិ ឱ្យមានលក្ខណៈកាន់តែប្រសើរឡើង និងជាសក្ខីភាពបញ្ជាក់ នូវការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ចំពោះស្ថានភាពជីវភាពរស់នៅរបស់ជនពិការ និងលើកស្ទួយសិទ្ធិ ព្រមទាំងការពារអត្ថប្រយោជន៍ជនពិការ សំដៅលុបបំបាត់រាល់រូបភាពរើសអើង ហើយនិងរក្សាបាននូវភាពសុខដុមរមនា ក្នុងសង្គមកម្ពុជាទាំងមូល។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមរដ្ឋសភាមេត្តាពិនិត្យ និងអនុម័តនូវសេចក្តីព្រាងច្បាប់ ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ដោយអនុគ្រោះ។

រាជធានីភ្នំពេញ ... ឆ្នាំ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

លេខ ..................... រ.ស.

**របាយការណ៍**

**ស្តីពី**

**ការពិនិត្យសិក្សាស្រាវជ្រាវលើអត្ថបទ**

**សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ**

- សូមគោរពសម្តេចអគ្គមហាពញាចក្រីប្រធានរដ្ឋសភា ជាទីគោរពដ៏ខ្ពង់ខ្ពស់

- សូមគោរពឯកឧត្តមអនុប្រធានទី១ ឯកឧត្តមអនុប្រធានទី២

- សូមគោរពលោកជំទាវ ឯកឧត្តម នៃអង្គសភាទាំងមូល

- សូមគោរពតំណាងរាជរដ្ឋាភិបាល

ក្នុងនាមគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងកិច្ចការនារី នាងខ្ញុំសូមអនុញ្ញាតជម្រាបជូនអង្គសភាទាំងមូលនូវលទ្ធផល នៃការពិនិត្យសិក្សាស្រាវជ្រាវលើអត្ថបទសេចក្តីព្រាងច្បាប់**ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ**។

១- <u>អំពីទម្រង់</u> :

សេចក្តីព្រាងច្បាប់នេះ ត្រូវបានរាជរដ្ឋាភិបាលបញ្ជូនមករដ្ឋសភា តាមលិខិតលេខ ១៥៨ លស.កបច ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ ដោយមានភ្ជាប់សេចក្តីថ្លែងហេតុ លេខ ០៨ សជណ.កបច ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ មកជាមួយផង។

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា បានប្រគល់ភារកិច្ច ជូនគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី តាមលិខិតលេខ ១៧៧ រស ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ ដើម្បីធ្វើការពិនិត្យសិក្សាស្រាវជ្រាវ និងចាត់ការធ្វើសេចក្តីរាយការណ៍ ជូនសភាពេញអង្គ។

សេចក្តីព្រាងច្បាប់នេះ មានទម្រង់រដ្ឋបាល ស្របតាមប្រការ ២១ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា។

ឆ្លើយតបចំពោះភារកិច្ច គណៈកម្មការបានប្រជុំផ្ទៃក្នុងគណៈកម្មការចំនួន ០២លើក ដោយមានការចូលរួមពីទីប្រឹក្សាច្បាប់អមគណៈកម្មការ។ តមក នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៩ គណៈកម្មការបានប្រជុំ ជាមួយតំណាងរាជរដ្ឋាភិបាល តំណាងគណៈកម្មការនានារដ្ឋសភា ទីប្រឹក្សាច្បាប់អមរដ្ឋសភា ទីប្រឹក្សាច្បាប់អមរដ្ឋសភា និងទីប្រឹក្សាច្បាប់អមគណៈកម្មការ ដើម្បីពិនិត្យពិភាក្សាលើខ្លឹមសារនៃសេចក្តីព្រាងច្បាប់នេះ។

គណៈកម្មការ និងតំណាងរដ្ឋាភិបាល បានឯកភាពគ្នាសម្រួល កែបន្ថែម និងលុបពាក្យពេចន៍ មួយចំនួនដូចខាងក្រោមនេះ :

<u>មាត្រា៤</u> :

នៅត្រទីពីរ បន្ទាត់ទីបី ប្តូរទីតាំងពាក្យ "**មន្ទីរ**" នៅពីមុខពាក្យ "**ស្ថាប័ន**" "...ក្រសួង ស្ថាប័ន **មន្ទីរ...**"

<u>មាត្រា៦</u> :

-នៅត្រទីបីបន្ថែមពាក្យ "**និង**" ចន្លោះពាក្យច្បាប់ និងពាក្យ**បទបញ្ជា**
"...គោលនយោបាយ ច្បាប់ **និង**បទបញ្ជាផ្សេងៗ..."

-នៅត្រទីបួនលុបពាក្យ"**ឬ**" ចន្លោះពាក្យ**បន្ថែម** និងពាក្យ**ធ្វើ** "...បំពេញបន្ថែម ធ្វើវិសោធនកម្ម..."
និងលុបពាក្យ"**ឬ**" ចន្លោះពាក្យ**ច្បាប់** និងពាក្យ**បទបញ្ជា** ដោយបន្ថែមពាក្យ "**និង**"
"...ច្បាប់ និងបទបញ្ជាផ្សេងៗ..."

<u>មាត្រា១២</u> :

នៅវាក្យខណ្ឌទីមួយ បន្ទាត់ទីពីរបន្ថែមគ្រែ និងសញ្ញាចុចពីរ នៅចន្លោះពាក្យ"**ដែល**"និងពាក្យ "**មាន**"និងនៅបន្ទាត់ទីបីក៏បន្ថែមគ្រែនៅចន្លោះពាក្យ"**ឬ**" និង ពាក្យ"**មាន**"

"...**ដើម្បីជួយឧបត្ថម្ភដល់ជនពិការ ដែល :**

**- មានកម្រិតពិការភាពធ្ងន់ធ្ងរ និងក្រីក្របំផុត និងគ្មានទីពឹង ឬ**

**- ចាស់ជរា និងក្រីក្របំផុត និងគ្មានទីពឹង ឬ**

**- មានគ្រោះថ្នាក់ធ្ងន់ធ្ងរ និងក្រីក្របំផុត និងគ្មានទីពឹង។"**

<u>មាត្រា៣២</u> :

នៅបន្ទាត់ទីមួយនៃវាក្យខណ្ឌទីពីរ លុបពាក្យ"**គោលការណ៍ឃោសនា**" បន្ថែមពាក្យ "**កម្មវិធីផ្សព្វផ្សាយ**" នៅចន្លោះពាក្យ"**មាន**"និងពាក្យ"**ពិសេស**"

"...ត្រូវមាន**កម្មវិធីផ្សព្វផ្សាយ**ពិសេស ចូលរួម..."

<u>មាត្រា៣៤</u> :

នៅបន្ទាត់ទីមួយនៃវាក្យខណ្ឌទីពីរលុបអក្សរ"**រ**" នៅចន្លោះពាក្យ"**សំណើ**" និងពាក្យ"**របស់**"

"...សំណើរបស់រដ្ឋមន្ត្រី..."

<u>មាត្រា៣៧</u> :

នៅវាក្យខណ្ឌទីពីរ បន្ទាត់ទីមួយ លុបពាក្យ"**វិ**" នៅចន្លោះពាក្យ"**បង់**"និងពាក្យ"**ភាគ**"

"អត្រានៃការបង់ភាគទាន..."

និងលុបអក្សរ"**រ**" នៅចន្លោះពាក្យ"**សំណើ**"និងពាក្យ"**របស់**" "...សំណើររបស់រដ្ឋមន្ត្រី..."

មាត្រា៤៤ :

នៅបន្ទាត់ទីពីរបន្ថែមឃ្លា "**រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**" នៅចន្លោះពាក្យ"**តាម**" និងពាក្យ"**ច្បាប់**" "...ស្របតាម**រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា** ច្បាប់ស្ដីពីការបោះឆ្នោត...។"

<u>មាត្រា៥៦</u> :

នៅបន្ទាត់ទីមួយបន្ថែមលេខ "**១**"នៅចន្លោះពាក្យ"**ពី**"និងពាក្យ" (**មួយ**)"

"...ដាក់ពន្ធនាគារពី ១ ( មួយ ) **ឆ្នាំ**..."

<u>មាត្រា៥៨</u> :

នៅបន្ទាត់ទីពីរនៃវាក្យខណ្ឌទីពីរបន្ថែមពាក្យ"**រៀល**" នៅចន្លោះពាក្យ"(**មួយលាន**)" និងសញ្ញា"**។**"

"...(មួយលាន)**រៀល**។"

<u>មាត្រា៥៩</u> :

នៅបន្ទាត់ទីពីរបន្ថែមលេខ"**១**" នៅពីមុខពាក្យ"**ពេល**" និងបន្ថែមសញ្ញា"**វង់ក្រចក**" នៅពីលើពាក្យ"មួយ"

"...រយៈពេល១ (មួយ)ឆ្នាំ..."

ក្រៅពីនោះ គណៈកម្មការ និងតំណាងរាជរដ្ឋាភិបាល បានឯកភាពរក្សាទុកខ្លឹមសារ និងទម្រង់នៃសេចក្ដីព្រាងលើកទី១ របស់រាជរដ្ឋាភិបាល ដូចមាននៅក្នុងអត្ថបទដែលបានថតចម្លងជូនតំណាងរាស្ត្រចំនួន ១២៣ រូប។

២- **ខ្លឹមសារសេចក្តីព្រាងច្បាប់** :

សេចក្តីព្រាងច្បាប់នេះ បានតាក់តែងឡើង ដោយអនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៧៤ ដែលចែងថា "រដ្ឋជួយឧបត្ថម្ភជនពិការ និងដល់គ្រួសារជនដែលបានបូជាជីវិត ដើម្បីប្រទេសជាតិ"។

កម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៣នៃរដ្ឋសភាបាន កំណត់គោលការណ៍វិធានការដើម្បី ការពារនិងលើកកម្ពស់សិទ្ធិជនពិការ ដោយបានសម្រេចដាក់បញ្ចូល សកម្មភាពកំចាត់មីន និងការជួយជនពិការដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះ ជាគោលដៅមួយក្នុងចំណោម គោលដៅអភិវឌ្ឍន៍សហសវត្សន៍កម្ពុជា ហើយនិងបានបញ្ជាក់ក្នុងសារលិខិតជូនជនពិការនិងជនរួមជាតិ ក្នុងទិវាជនពិការអន្តរជាតិ ថ្ងៃទី០៣ ខែធ្នូ ជារៀងរាល់ឆ្នាំ ដើម្បីលើកស្ទួយសិទ្ធិជនពិការនិងជីវភាពរស់នៅរបស់បងប្អូនជនពិការឱ្យបានប្រសើរឡើង។

សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិ ជនពិការអាចជួយឱ្យគ្រប់ផ្នែក និងវិស័យទាំងអស់ ស្រូបទាញយកសក្តានុពលភាពរបស់ជនពិការ ហើយជួយដល់ជនពិការ និងសាធារណជនឱ្យមានការយល់ដឹង មានទំនុកចិត្ត និងមានសេចក្តីសង្ឃឹម ហើយអាចផ្លាស់ប្តូរផ្នត់គំនិត ឬទស្សនៈដែលយល់ថា ជនពិការជាជនត្រូវស្ថិតទាំងស្រុងក្នុងការទទួលខុសត្រូវពី បន្ទុកគ្រួសារ និងសង្គម។

សេចក្តីព្រាងច្បាប់នេះ មាន ១៤ ជំពូក និង ៦០មាត្រា។

៣- **សេចក្តីសន្និដ្ឋាន** :

គណៈកម្មការយល់ឃើញថា សេចក្តីព្រាងច្បាប់**ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ** មានលក្ខណៈសមស្របទាំងខាងទម្រង់រដ្ឋបាលនិងទាំងខាងខ្លឹមសារដែលអាចដាក់ជូនអង្គសភាពពិភាក្សានិងអនុម័តបាន។

អាស្រ័យហេតុនេះ សូមអង្គសភាទាំងមូល មេត្តាពិភាក្សានិងអនុម័តសេចក្តីព្រាងច្បាប់នេះមួយជំពូកម្តងៗ ដោយអនុគ្រោះ។

**សូមអរគុណ ។**

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែ មេសា ឆ្នាំ ២០០៩

**ត.គណៈកម្មការ**

**ប្រធាន**

**ហូ ណាង**